# <u>អារម្ភកថា</u>

ខ្ញុំបាទឈ្មោះ អាន តាំងគីម កើតនៅឆ្នាំ ១៩៤២ រស់នៅប្រទេសបារាំងចាប់តាំងពីឆ្នាំ ១៩៧៣ ជាអតីតសាស្ត្រាចារ្យ ទុតិយភូមិផ្នែកគណិតសាស្ត្រ ចេញពីសាលាគរុកោសលជាន់ខ្ពស់ ក្រុងភ្នំពេញ ធ្លាប់បង្ហាត់ថ្នាក់ទីបញ្ចប់នៃវិទ្យាល័យនានា នៅខេត្ត និងនៅក្រុងភ្នំពេញ ។

ខ្ញុំសរសេរអត្ថបទដូចមានខាងក្រោមនេះ ដោយមានបំណងចង់ឲ្យមានឯកសារគ្រប់មុខវិជ្ជា <u>ជាភាសាខ្មែរ ឲ្យបានច្រើន</u> ។ ដោយខ្ញុំធ្លាប់បានរៀនគណិតសាស្ត្រ នោះខ្ញុំក៏សរសេរគណិតសាស្ត្រទៅ តាមតែចំណេះរបស់ខ្ញុំដែលនៅសល់ ដោយខ្ញុំយល់ឃើញថា អាចជាប្រយោជន៍ទៅថ្ងៃក្រោយ។ តែសូមកុំយល់ថាខ្មែរយើងគ្មានឯកសារជាភាសាខ្មែរនោះឲ្យសោះ ។ ខ្ញុំគ្រាន់តែមានគំនិតចង់ឲ្យមានឯកសារច្រើនតែប៉ុណ្ណោះ។
ទុកជានៅបរទេស ក៏មានសៀវភៅជាច្រើនសរសេរលើមុខវិជ្ជាតែមួយ ដោយអ្នកនិពន្ធផ្សេងៗគ្នាដែរ នេះជាប្រយោជន៍មួយដល់សិស្សដែលមើលសៀវភៅមួយមិនយល់ នោះអាចរកការពន្យល់ នៅសៀវភៅផ្សេងទៀតបាន ថ្វីបើទ្រឹស្តីតែមួយក៏ដោយ ។ យើងឃើញហើយ ព្រះសង្ឃលោកទេសនា លោកពន្យល់ធម៌ព្រះពុទ្ធតែមួយ តែរបៀបពន្យល់ ក៏អាចខុសគ្នាពីព្រះសង្ឃមួយ ទៅព្រះសង្ឃមួយដែរ។
បំណងខ្ញុំចង់តែឲ្យលោកអ្នកអានបានយល់ដូចបំណងទេ តែបើសិនជាមិនបានសម្រេចដូចបំណងវិញ ឬមានការខុសឆ្គងយ៉ាងណា នោះសូមមេត្តាអធ្យាស្រ័យឲ្យខ្ញុំផងចុះ ។
ឯកសារដូចតទៅនេះ មានកំរិតត្រឹមតែថ្នាក់ទី ១២ ឬ ថ្នាក់ឆ្នាំដំបូងនៅមហាវិទ្យាល័យ ព្រោះខ្ញុំយល់ថា អាចមាននិស្សិតខ្លះពុំទាន់ស្ទាត់នៅឡើយក្នុងការអានឯកសារជាភាសាបរទេស ដូចជាអង់គ្លេសជាដើម។
<u>សង្កេត</u> :

*ចំពោះពាក្យគណិតសាស្ត្រ ឬ ពាក្យបច្ចេកទេសខ្លះ ដែលខ្ញុំរកពុំទាន់ឃើញក្នុងសៀវភៅខេមរយានកម្ម ខ្ញុំសូមអនុញ្ញាត<u>ទុកជាភាសាដើមសិន</u> ដោយខ្ញុំសរសេរជាអក្សរខ្មែរ ហើយក្នុងវង្វង់ក្រចកជាពាក្យបារាំង (ព្រោះខ្ញុំចេះតែពាក្យបារាំង)។ ឧទាហរណ៍ដូចជា អាំងសេចទីវ* (injective) *ជាដើម។*

*ចំពោះលោកអ្នកអាន មិនជាចំណោទទេ ព្រោះពាក្យទាំងនោះ សុទ្ធតែមានន័យមន័យជាភាសាខ្មែរ ។*

**អត្ថបទទាំងអស់ អាចយកទៅជួយផ្សាយជាធម្មទានបាន** ៕